# តើនៅថ្ងៃនេះខ្ញុំបានធ្វើអ្វីខ្លះចំពោះមនុស្សម្នាក់?

ប្រធាន ថូម៉ាស អេស ម៉នសុន

*សេចក្តីត្រូវការរបស់អ្នកដទៃតែងកើតមានជានិច្ច ហើយយើងម្នាក់ៗអាចធ្វើអ្វីមួយ ដើម្បីជួយដល់មនុស្សម្នាក់ទៀតបាន ។*

បងប្អូនប្រុសស្រីជាទីស្រឡាញ់របស់ខ្ញុំ នៅពេលព្រឹកនេះ ខ្ញុំសូមស្វាគមន៍ដល់អ្នករាល់គ្នា ដោយនូវសេចក្តីស្រឡាញ់ក្នុងដួងចិត្តរបស់ខ្ញុំចំពោះដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ និងចំពោះអ្នករាល់គ្នាគ្រប់រូប ។ ខ្ញុំមានអំណរគុណណាស់ ចំពោះឯកសិទ្ធិដើម្បីឈរនៅចំពោះមុខអ្នករាល់គ្នា ហើយខ្ញុំសូមអធិស្ឋានថា ខ្ញុំអាចនិយាយទៅកាន់អ្នករាល់គ្នានូវអ្វីដែលខ្ញុំត្រូវបានបំផុសគំនិតឱ្យនិយាយប្រកបដោយប្រសិទ្ធភាព ។

កាលពីប៉ុន្មានឆ្នាំមុន ខ្ញុំបានអានអត្ថបទមួយដែលនិពន្ធដោយលោក ចាក ម៉ាកខូណេល ជាវិជ្ជបណ្ឌិតផ្នែកវេជ្ជសាស្ត្រ ។ គាត់បានចំរើនវ័យឡើងនៅក្នុងតំបន់ភ្នំ ភាគនិរតីនៃរដ្ឋវើរជីនញ៉ា ក្នុងសហរដ្ឋអាមេរិក ជាកូនម្នាក់នៅក្នុងចំណោមកូនទាំងប្រាំពីរនាក់របស់គ្រូគង្វាលនិកាយមេថូឌីសម្នាក់ និងមានម្តាយដែលជាមេផ្ទះ ។ ពួកគាត់មានជីវភាពក្រខ្សត់ណាស់ ។ គាត់បានរៀបរាប់ថា កាលពីនៅក្មេង ជារៀងរាល់ថ្ងៃ នៅពេលគ្រួសាររបស់គាត់បានអង្គុយជុំវិញតុបាយសំរាប់អាហារពេលល្ងាច នោះឪពុករបស់គាត់បានសួរដល់កូនគ្រប់គ្នាម្តងម្នាក់ៗថា "តើនៅថ្ងៃនេះតើកូនបានធ្វើអ្វីខ្លះចំពោះមនុស្សម្នាក់?"1 កូនគ្រប់គ្នាត្រូវបានតាំងចិត្តធ្វើការបំរើដ៏ល្អមួយជារៀងរាល់ថ្ងៃ ដើម្បីពួកគេអាចរាយការណ៍ទៅកាន់ឪពុករបស់ខ្លួនវិញថា ពួកគេបានជួយដល់មនុស្សម្នាក់ ។ លោកវេជ្ជបណ្ឌិតម៉ាកខូណេល បានហៅកិច្ចការនេះថាជា កេរមរតកដ៏មានតម្លៃបំផុតរបស់ឪពុកគាត់ ត្បិតការរំពឹងទុក *នោះ* និងពាក្យសម្តី *ទាំងនោះ* បានបំផុសគំនិតគាត់ និងបងប្អូនរបស់គាត់ឱ្យជួយដល់អ្នកដទៃនៅក្នុងជីវិតរស់នៅរបស់ខ្លួន ។ នៅពេលពួកគេបានចំរើនវ័យធំឡើង នោះការលើកទឹកចិត្តពួកគាត់ឱ្យមានការបំរើ បានប្រែក្លាយទៅជាបំណងប្រាថ្នាចេញពីដួងចិត្ត ដើម្បីជួយដល់អ្នកដទៃ ។

ក្រៅពីអាជីពផ្នែកវេជ្ជសាស្ត្រដ៏មានកេរ្តិ៍ឈ្មោះរបស់លោកវេជ្ជបណ្ឌិត ម៉ាកខូណេល ជាអាជីពមួយដែលបានដឹកនាំការអភិវឌ្ឍន៍លើការសាកល្បងជម្ងឺរបេងស្បែក និងបានចូលរួមក្នុងការបង្កើតថ្នាំការពាររោគខួរឆ្អឹងខ្នងដំបូងគេ និងបានគ្រប់គ្រងលើការស្រាវជ្រាវថ្នាំទីឡេណុល និងធ្វើជាផ្នែកដ៏សំខាន់មួយនៅក្នុងការអភិវឌ្ឍន៍នៃដំណើរការបង្កើតគុណភាពមេដែក ឬអិម.អ័រ.អាយ នោះគាត់បានបង្កើតអង្គការមួយដែលគាត់ដាក់ឈ្មោះថា ពួកអ្នកស្ម័គ្រចិត្តផ្នែកវេជ្ជសាស្ត្រ ដែលផ្តល់ឱកាសឱ្យពួកគ្រូពេទ្យផ្នែកវេជ្ជសាស្ត្រចូលនិវត្តន៍ ដើម្បីស្ម័គ្រចិត្តនៅតាមគ្លីនិកដែលព្យាបាលដោយឥតបង់ថ្លៃ ដល់ពួកកម្មករដែលគ្មានការធានារ៉ាប់រងផ្នែសុខភាពនោះ ។ លោកវេជ្ជបណ្ឌិត ម៉ាកខូណេល បានមានប្រសាសន៍ថា ពេលទំនេររបស់គាត់ ចាប់តាំងពីគាត់បានចូលនិវត្តន៍មក "គឺត្រូវបានដកយកចំនួន 60 ម៉ោងក្នុងសប្តាហ៍សំរាប់ការងារដែលមិនបានទទួលកំរៃ ប៉ុន្តែកម្លាំង[របស់គាត់]បានមានការកើនឡើង ហើយជីវិត [គាត់] មានភាពរីករាយលើសពីមុនទៅទៀត" ។ គាត់លើកឡើងថា: "ចំពោះការផ្លាស់ប្តូរជីវិតមួយបែបនេះ ខ្ញុំបានទទួលអត្ថប្រយោជន៍យ៉ាងច្រើនពីពួកអ្នកស្ម័គ្រចិត្តផ្នែកវេជ្ជសាស្ត្រជាងពួកអ្នកជម្ងឺរបស់ខ្ញុំ" ។2 ឥឡូវនេះមានគ្លីនិកបែបនេះច្រើនជាង 70 កន្លែង នៅទូទាំងសហរដ្ឋអាមេរិក ។

ពិតណាស់ យើងមិនអាចធ្វើដូចជាលោកវេជ្ជបណ្ឌិត ម៉ាកខូណេល ដោយបង្កើតគ្លីនិកវេជ្ជសាស្ត្រដើម្បីជួយដល់អ្នកក្រីក្របានឡើយ ប៉ុន្តែសេចក្តីត្រូវការរបស់អ្នកដទៃតែងកើតមានជានិច្ច ហើយយើងម្នាក់ៗអាចធ្វើអ្វីមួយ ដើម្បីជួយដល់មនុស្សម្នាក់ទៀតបាន។

សាវក ប៉ុល បានទូន្មានថា ចូរ"បំរើគ្នាទៅវិញទៅមកដោយសេចក្តីស្រឡាញ់"។3 សូមរំលឹកឡើងវិញជាមួយនឹងខ្ញុំនូវពាក្យសម្តីស្រដៀងគ្នានេះដែរ របស់ស្តេចបេនយ៉ាមីន នៅក្នុងព្រះគម្ពីរមរមនថា: "កាលណាអ្នករាល់គ្នានៅក្នុងការបំរើដល់មនុស្សទូទៅ នោះអ្នករាល់គ្នាគ្រាន់តែនៅក្នុងកាបំរើដល់ព្រះរបស់អ្នកតែប៉ុណ្ណោះ"។4

ព្រះអង្គសង្គ្រោះបានបង្រៀនដល់ពួកសិស្សរបស់ទ្រង់ថា "ត្បិតអ្នកណាដែលចង់ឱ្យរួចជីវិត នោះនឹងបាត់ជីវិតទៅ តែអ្នកណាដែលបាត់ជីវិតដោយព្រោះខ្ញុំ នោះនឹងបានជីវិតវិញ"។5

ខ្ញុំជឿជាក់ថា ព្រះអង្គសង្គ្រោះកំពុងតែមានបន្ទូលប្រាប់យើងថា លើកលែងតែយើងលះបង់ខ្លួនឯងនៅក្នុងការបំរើដល់អ្នកដទៃ បើពុំនោះសោតទេ ជីវិតផ្ទាល់ខ្លួនរបស់យើង គឺមានគោលបំណងតូចបំផុត។ ពួកអ្នកដែលរស់នៅសំរាប់តែខ្លួនឯង នៅទីបំផុតនឹងចុះថយខាងវិញ្ញាណ ហើយវាប្រៀបបាននឹងការបាត់បង់ជីវិតរបស់ខ្លួនដូច្នោះដែរ។ ផ្ទុយទៅវិញ ពួកអ្នកដែលលះបង់ខ្លួនឯងនៅក្នុងការបំរើល់អ្នកដទៃនឹងរីកចំរើនកាន់តែច្រើនឡើងៗ---ហើយជាលទ្ធផល នោះជីវិតរបស់ពួកគេនឹងទទួលបានការសង្គ្រោះ។

នៅក្នុងសន្និសីទទូទៅខែ តុលា ឆ្នាំ 1963---ជាសន្និសីទដែលខ្ញុំបានទទួលការគាំទ្រធ្វើជាសមាជិកក្រុមនៃពួកសាវកដប់ពីរនាក់---នៅក្នុងឱកាសនោះ ប្រធាន ដេវីឌ អូ មិកឃេ បានមានប្រសាសន៍បែបនេះថា : "សុភមង្គលដ៏ធំបំផុតរបស់មនុស្សម្នាក់កើតចេញពីការលះបង់ខ្លួនឯងសំរាប់សេចក្តីល្អរបស់អ្នកដទៃ"។6

ជាញឹកញាប់ យើងរស់នៅក្បែរគ្នាក៏ពិតមែន ប៉ុន្តែយើងមិនបានធ្វើការប្រាស្រ័យទាក់ទងចេញពីដួងចិត្តនោះឡើយ។ នៅតាមតំបន់ដែលយើងគ្រប់គ្រង គឺមានពួកអ្នកដែលកំពុងលាតសន្ធឹងដៃរបស់ខ្លួន ហើយស្រែកឡើងថា "តើគ្មានប្រទាលមុខសេះនៅក្រុងកាឡាតទេឬអី?"7

ខ្ញុំជឿជាក់យ៉ាងខ្លាំងថា សមាជិកសាសនាចក្រម្នាក់ៗមាន *បំណង* ដើម្បីបំរើ និងជួយដល់ពួកអ្នកដែលមានសេចក្តីត្រូវការ។ នៅពេលទទួលបុណ្យជ្រមុជទឹក យើងធ្វើសេចក្តីសញ្ញា ដើម្បី "ទទួលបន្ទុកគ្នាទៅវិញទៅមក ដើម្បីឱ្យបន្ទុកនោះបានស្រាល"។8 នៅពេលអ្នករាល់គ្នាមើលឃើញពីសេចក្តីត្រូវការរបស់មនុស្សម្នាក់ទៀត តើដួងចិត្តរបស់អ្នកមានក្តីអាណិតអាសូរប៉ុន្មានដងដែរ? តើអ្នករាល់គ្នាធ្លាប់មាន *បំណង* ដើម្បីធ្វើជាមនុស្សម្នាក់ដែលចាំជួយបានញឹកញាប់ប៉ុណ្ណាដែរ? ហើយជាងនេះទៀត តើការរស់នៅប្រចាំថ្ងៃបានបង្អាក់មិនឱ្យធ្វើអ្វីសោះ ដោយគតិថា "ប្រាកដជាមានមនុស្សផ្សេងទៀតនឹងដោះស្រាយចំពោះសេចក្តីត្រូវការនោះជាពុំខានឡើយប៉ុន្មានដងដែរ"។

យើងចាប់ផ្តើមខ្វល់ខ្វាយចំពោះភាពមមាញឹកនៅក្នុងជីវិតរស់នៅរបស់យើង។ ប៉ុន្តែ បើយើងឈប់មួយភ្លែត ហើយសម្លឹងមើលទៅលើទង្វើររបស់យើង នោះប្រហែលជាអាចរកឃើញថា យើងកំពុងតែដឹកនាំខ្លួនឱ្យចូលប្រឡូកនៅក្នុង "រឿងដែលមិនសូវសំខាន់"

ជាពុំខានឡើយ។ បើនិយាយម្យ៉ាងទៀត គឺថាជាញឹកញាប់ យើងបានចំណាយពេលរបស់យើងជាច្រើនខ្វល់ខ្វាយចំពោះរឿងដែលមិនសូវសំខាន់នៅក្នុងជីវិត ហើយបែរជាមិនអើពើនឹងរឿងដែលសំខាន់បំផុតទៅវិញ។

ជាច្រើនឆ្នាំកន្លងទៅ ខ្ញុំបានឮកំណាព្យមួយដែលបានដក់ជាប់នៅក្នុងដួងចិត្តរបស់ខ្ញុំ ដែលខ្ញុំបានព្យាយាមដឹកនាំជីវិតរបស់ខ្ញុំស្របតាមពាក្យពេចន៍ទាំងនោះ។ នេះគឺជាកំណាព្យមួយដែលខ្ញុំចូលចិត្ត ៖

*ខ្ញុំសំរក់ទឹកភ្នែកនាពេលរាត្រី*
*ត្បិតអី ការខ្វះវិញ្ញាណយល់ដឹង*
*បានធ្វើឱ្យខ្ញុំមើលពុំឃើញពីសេចក្តីត្រូវការរបស់អ្នកដទៃ*
*តែចិត្តសោកសៅ*
*ចំពោះការធ្វើអំពើល្អ*
*គឺខ្ញុំពុំដែលមានឡើយ ។9*

បងប្អូនប្រុសស្រីទាំងឡាយ យើងរុំព័ទ្ធទៅដោយពួកអ្នកដែលត្រូវការ ការយកចិត្តទុកដាក់ ការលើកទឹកចិត្ត ការគាំទ្រ ការលួងលោម និងសណ្តានចិត្តរបស់យើង---មិនថាពួកគេជាសមាជិកគ្រួសារ ជាមិត្តភក្តិ ជាអ្នកស្គាល់គ្នា ឬជាមនុស្សចម្លែកនោះឡើយ។ យើងគឺជាព្រះពាហុរបស់ព្រះអម្ចាស់នៅលើផែនដីនេះ ដែលត្រូវបានបញ្ជាឱ្យបំរើ និងលើកស្ទួយដល់កូនចៅរបស់ទ្រង់។ ទ្រង់ពឹងផ្អែកទៅលើយើងគ្រប់គ្នា។

អ្នករាល់គ្នាអាចនឹងតួញត្អែរថា ៖ ដោយខិតខំអស់ពីលទ្ធភាព ខ្ញុំស្ទើរតែរកមួយថ្ងៃសំរាប់មួយថ្ងៃមិនបានផង។ តើខ្ញុំអាចធ្វើការបំរើដល់អ្នកដទៃបានដោយរបៀបណា? តើអ្វីខ្លះដែលខ្ញុំអាចធ្វើទៅបាននោះ?

កាលពីជាងមួយឆ្នាំមុននេះ ខ្ញុំបានជួបសម្ភាសជាមួយអ្នកសារព័ត៌មានរបស់សាសនាចក្រ ពីមុនថ្ងៃខួបកំណើតរបស់ខ្ញុំ។ នៅចុងបញ្ចប់នៃការសម្ភាសន៍នោះ អ្នកសារព័ត៌មានរូបនោះបានសួរថា តើអ្វីទៅដែលខ្ញុំគិតថាជាអំណោយដ៏ប្រពៃមួយ ដែលសមាជិកនៅជុំវិញពិភពលោកអាចផ្តល់ឱ្យខ្ញុំបាន។ ខ្ញុំបានឆ្លើយតបថា "ចូរស្វែងរកមនុស្សម្នាក់ដែលមានទុក្ខលំបាក ឬមានជម្ងឺ ឬមានភាពឯកកោ រួចហើយចូរធ្វើអ្វីមួយសំរាប់ពួកគេ"។10

ខ្ញុំមានចិត្តរំភើបខ្លាំងណាស់ ដោយសារខួបកំណើតរបស់ខ្ញុំនៅឆ្នាំនេះ ខ្ញុំបានទទួលប័ណ្ណជូនពរ និងសំបុត្រយ៉ាងច្រើនមកពីសមាជិកសាសនាចក្រនៅជុំវិញពិភពលោក ដោយពួកគេបានប្រាប់ខ្ញុំពីរបៀបដែលបានបំពេញតាមបំណងប្រាថ្នាសំរាប់ថ្ងៃខួបកំណើតរបស់ខ្ញុំ។ ទង្វើរនៃការបំរើទាំងនេះបានមានចាប់ពីការរៀបចំគ្រឿងបរិក្ខាមនុស្សធម៌ រហូតដល់ការធ្វើកិច្ចការតាមបរិវេណផ្ទះ។

មានអង្គការបឋមសិក្សាជាច្រើនបានសុំឱ្យកុមារទាំងឡាយធ្វើការបំរើ រួចហើយទង្វើរនៃការបំរើទាំងនោះត្រូវបានកត់ត្រាទុកហើយបានផ្ញើមកឱ្យខ្ញុំ។ ខ្ញុំត្រូវនិយាយថា វិធីសាស្រ្តនៃការកត់ត្រាសកម្មភាពទាំងនោះ គឺជាភាពប៉ិនប្រសប់មួយ។ មានអំណោយ

ជាច្រើនបានផ្ញើមកជាសៀវភៅដែលរាង និងទំហំផ្សេងៗពីគ្នា។ ខ្លះទៀតមានជាប័ណ្ណជូនពរ ឬរូបភាពដែលគូរ ឬផាត់ពណ៌ដោយកុមារ។ អំណោយដ៏ប៉ិនប្រសប់មួយរបស់អង្គការបឋមសិក្សាបានផ្ញើឱ្យខ្ញុំនូវក្រឡមួយដែលមានវត្ថុតូចៗរាប់រយ ដែលពួកគេហៅថា "វត្ថុតូចៗដ៏កក់ក្ដៅ"។ វត្ថុនិមួយៗតំណាងឱ្យទង្វើរនៃការបំរើដែលបានធ្វើនៅក្នុងរយៈពេលមួយឆ្នាំ ដោយកុមារម្នាក់នៅក្នុងអង្គការបឋមសិក្សា។ ខ្ញុំអាចស្រមើស្រមៃឃើញពីភាពរីករាយដែលកុមារទាំងនេះមាន នៅពេលពួកគេរៀបរាប់ពីការបំរើរបស់ខ្លួនរួចហើយដាក់ "វត្ថុតូចៗដ៏កក់ក្ដៅ" នោះចូលទៅក្នុងក្រឡ។

ខ្ញុំសូមចែកចាយនឹងអ្នករាល់គ្នាតែលិខិតមួយចំនួនប៉ុណ្ណោះ នៅក្នុងចំណោមលិខិតជាច្រើនដែលមាននៅក្នុងអំណោយជាច្រើនដែលខ្ញុំបានទទួល។ មានកុមារតូចម្នាក់បានសរសេរថា "លោកតារបស់ខ្ញុំមានជម្ងឺដាច់សរសៃឈាមខួរក្បាល ហើយខ្ញុំបានកាន់ដៃរបស់គាត់"។ មានក្មេងស្រីអាយុ 8 ឆ្នាំបានសរសេរថាៈ "បងស្រីខ្ញុំ ហើយនឹងរូបខ្ញុំបានបំរើដល់អ្នកម៉ាក់របស់ខ្ញុំ និងគ្រួសារ តាមរយៈការរៀបចំ និងសំអាតទូដាក់របស់ក្មេងលេង។ យើងបានចំណាយពេលធ្វើកិច្ចការនោះអស់រយៈពេលពីរទៅបីម៉ោង ហើយយើងមានក្ដីរីករាយជាខ្លាំង។ ផ្នែកដ៏សំខាន់បំផុតនោះគឺថា យើងបានធ្វើឱ្យអ្នកម៉ាក់ភ្ញាក់ផ្អើល ហើយបានធ្វើឱ្យគាត់សប្បាយចិត្ត ពីព្រោះគាត់មិនបានសុំឱ្យយើងធ្វើកិច្ចការនេះឡើយ"។ ក្មេងស្រីអាយុ 11 ម្នាក់បានសរសេរថាៈ "នៅក្នុងវួដរបស់ខ្ញុំ មានគ្រួសារមួយដែលពុំសូវធូរធាប៉ុន្មានទេ។ ពួកគាត់មានកូនស្រីតូចៗបីនាក់។ បុរសដែលជាប្ដី និងភរិយារបស់គាត់គឺត្រូវការចេញទៅក្រៅ ដូច្នេះខ្ញុំក៏បានស្ម័គ្រខ្លួនជួយមើលក្មេងស្រីទាំងបីនាក់នោះ។ បុរសជាប្ដីរៀបនឹងហុចប្រាក់ 5 ដុល្លារ ឱ្យខ្ញុំ។ ប៉ុន្តែ ខ្ញុំបាននិយាយថា 'ខ្ញុំមិនយក [ប្រាក់] នេះទេ'។ ការបំរើរបស់ខ្ញុំ គឺខ្ញុំបានមើលក្មេងស្រីទាំងនោះដោយឥតគិតពីកំរៃ"។ មានកុមារម្នាក់នៅក្នុងអង្គការបឋមសិក្សានៃប្រទេសមុងហ្គោលី បានសរសេរថាៈ គាត់បានដងទឹកចេញពីអណ្ដូង ដូច្នេះអ្នកម្ដាយរបស់គាត់នឹងពុំចាំបាច់ត្រូវធ្វើកិច្ចការនេះទៀតឡើយ។ ក្មេងប្រុសម្នាក់អាយុ 4 ឆ្នាំ កុំមានការសង្ស័យឡើយ គឺគ្រូបង្រៀនថ្នាក់កុមារជួយសរសេរឱ្យគាត់ថា : "លោកប៉ារបស់ខ្ញុំបានទៅចូលរួមការបំពាក់បំប៉នកងទ័ពរយៈពេលពីរទៅបីសប្ដាហ៍។ កិច្ចការដ៏សំខាន់របស់ខ្ញុំ គឺឱប ហើយនឹងថើបអ្នកម៉ាក់របស់ខ្ញុំ"។ មានក្មេងស្រីម្នាក់ អាយុ 9 ឆ្នាំ បានសរសេរថា : "ខ្ញុំបេះផ្លែស្ត្រ័របឺរី សំរាប់ជូនជីដូនរបស់ខ្ញុំ។ ខ្ញុំបានមានអារម្មណ៍ល្អនៅក្នុងចិត្ត!" ហើយមានក្មេងស្រីម្នាក់ទៀតបានសរសេរថា : "ខ្ញុំបានលេងជាមួយនឹងក្មេងដែលមានភាពឯកកោ"។

មានក្មេងប្រុសអាយុ 11 ឆ្នាំ បាននិយាយថាៈ "ខ្ញុំបានទៅផ្ទះរបស់ស្ត្រីម្នាក់ ហើយសួរសំណួរមួយចំនួនដល់គាត់ ហើយបានច្រៀងចម្រៀងមួយបទឱ្យគាត់ស្ដាប់។ ខ្ញុំមានអារម្មណ៍ល្អ នៅពេលបានទៅលេងគាត់។ គាត់មានចិត្តរីករាយ ពីព្រោះគាត់ពុំធ្លាប់មានអ្នកមកលេងឡើយ"។ ការអាននូវលិខិតទាំងនេះបានធ្វើឱ្យខ្ញុំនឹកចាំពីពាក្យពេចន៍ដែលបានសរសេរទុកជាយូរមកហើយ ដោយអែលឌើរ រីឆាត អិល អ៊ីវ៉ាន់ ក្នុងក្រុមនៃពួកដប់ពីរនាក់។ លោកបានមានប្រសាសន៍ថា : "វាពុំមែនជាការងាយស្រួលឡើយ ដើម្បីធ្វើឱ្យពួកមនុស្សវ័យក្មេងយល់ពីភាពឯកកោ ដែលកើតឡើងនៅពេលជីវិតមានការផ្លាស់ប្ដូរ ពីពេលដែលយើងចាប់ផ្ដើមជីវិតធ្វើការរហូតដល់ពេលយើងមានភាពថយចុះក្នុងការប្រឡូកនៃជីវិតនេះ...។ កាលពីដំបូងឡើយ មានការផ្ដោតយកចិត្តទុកដាក់ច្រើនចំពោះរឿងនៅក្នុងផ្ទះសម្បែង ប៉ុន្តែក្រោយមកក៏បាត់បង់ចំណូលចិត្ត ដោយសម្លឹងមើលអ្នកដទៃរស់នៅតាមជីវិតរបស់ខ្លួន---នេះគឺ ជាការរស់នៅក្នុងភាពឯកកោ...។ យើងត្រូវរស់នៅឱ្យបានយូរ ដើម្បីរៀនថាតើបន្ទប់មួយដែលមានតែសាឡុងនោះ វាមានភាពទទេរស្អាតបែបណា។ វាត្រូវការមនុស្សម្នាក់...ដែលបំរើដោយចិត្តស្មោះ ឬពុំដោយសារវាជាកាតព្វកិច្ចរបស់ខ្លួននោះឡើយ ដើម្បីនាំយកត្រឡប់មកវិញនូវអនុស្សាវរីយពីអតីតកាល ហើយធ្វើឱ្យមនុស្សបែបនេះរស់នៅដោយរីករាយសំរាប់ពេលបច្ចុប្បន្ន...។

យើងមិនអាចនាំពួកគេទៅកាន់ភាពជាយុវវ័យរបស់ខ្លួនបានវិញឡើយ។ ប៉ុន្តែ យើងអាចជួយគេឱ្យរស់នៅក្នុងភាពកក់ក្តៅនៃជីវិតចុងក្រោយរបស់ពួកគេ ដែលកាន់តែធ្វើឱ្យមានភាពស្រស់បំព្រងថែមទៀត តាមរយៈការខ្វល់ខ្វាយ... និងសេចក្តីស្រឡាញ់ដ៏ស្មោះរបស់យើង"។11

ប័ណ្ណ និងលិខិតជូនពរសំរាប់ថ្ងៃខួបកំណើតរបស់ខ្ញុំ ក៏ទទួលបានមកពីក្មេងជំទង់នៅក្នុងថ្នាក់យុវជនយុវនារីជាច្រើនផងដែរ ដែលពួកគេបានធ្វើភួយសំរាប់បរិច្ចាគដល់មន្ទីរពេទ្យ បានបំរើនៅកន្លែងដែលផ្តល់ម្ហូបដល់មនុស្សក្រីក្រ បានធ្វើបុណ្យជ្រមុជទឹកសំរាប់មរណជន និងបានធ្វើការបំរើដ៏ច្រើនរាប់មិនអស់ផ្សេងទៀត។

សមាគមសង្គ្រោះទាំងឡាយ ដែលបានតែងតែរៀបចំខ្លួនជួយជានិច្ចនោះ បានធ្វើការបំរើជាច្រើន គឺលើសពីអ្វីដែលពួកគេធ្លាប់ធ្វើពីមុនមកទៅទៀត។ ក្រុមបព្វជិតភាពក៏បានធ្វើដូចគ្នានេះផងដែរ។

បងប្អូនប្រុសស្រីទាំងឡាយរបស់ខ្ញុំ ដួងចិត្តរបស់ខ្ញុំមានក្តីរំភើប និងមានអំណរគុណស្មើរតែគ្រប់ពេលដែលស៊ិស្ទើរ ម៉នសុន ហើយនឹងរូបខ្ញុំបានចំណាយពេលជាច្រើនម៉ោង ដើម្បីអាននូវលិខិតទាំងនេះ។ ឥឡូវនេះ ដួងចិត្តរបស់ខ្ញុំមានក្តីរីករាយខ្លាំងណាស់ នៅពេលខ្ញុំលើកឡើងពីបទពិសោធន៍នេះ ហើយគិតពីពរជ័យដែលកើតមានដល់ជីវិតរបស់អ្នកផ្តល់ឱ្យ និងអ្នកទទួល។

ព្រះបន្ទូលនៅក្នុងម៉ាថាយជំពូកទី 25 បានផុសឡើងនៅក្នុងគំនិតរបស់ខ្ញុំថា: "ឱពួកអ្នកដែលព្រះវរបិតាយើងបានប្រទានពរអើយ ចូរមកទទួលមរតកចុះ គឺជានគរដែលបានរៀបចំទុកសំរាប់អ្នករាល់គ្នាតាំងពីកំណើតលោកិយមកៈ

"ពីព្រោះយើងបានឃ្លាន ហើយ អ្នករាល់គ្នាបានបរិភោគ យើងស្រេក ហើយអ្នករាល់គ្នាបានឱ្យផឹក យើងជាអ្នកដទៃ ហើយអ្នករាល់គ្នាបានទទួលយើងៈ

"យើងនៅអាក្រាត ហើយអ្នករាល់គ្នាបានស្លៀកពាក់ឱ្យយើង យើងបានឈឺ ហើយអ្នករាល់គ្នាបានមកសួរយើង ក៏ជាប់គុក ហើយអ្នករាល់គ្នាបានមកឯយើង។

"នោះពួកមនុស្សសុចរិតនឹងទូលសួរទ្រង់ថា ព្រះអម្ចាស់អើយ តើយើងខ្ញុំបានឃើញទ្រង់ស្រេកឃ្លាន ហើយបានថ្វាយទ្រង់សោយពីកាលណា?

"តើយើងខ្ញុំបានឃើញទ្រង់ជាមនុស្សដទៃ ហើយបានទទួលទ្រង់ពីកាលណា? ឬទ្រង់អាក្រាត ហើយបានបំពាក់ថ្វាយទ្រង់ពីកាលណា?

"តើយើងខ្ញុំបានឃើញទ្រង់ឈឺ ឬជាប់គុក ហើយបានមកឯទ្រង់ពីកាលណា?

"នោះស្ដេចនឹងឆ្លើយទៅគេថា យើងប្រាប់អ្នករាល់គ្នាជាប្រាកដថា ដែលអ្នករាល់គ្នាបានធ្វើការទាំងនោះដល់អ្នកតូចបំផុតក្នុងពួកបងប្អូនយើងនេះ នោះឈ្មោះថាបានធ្វើដល់យើងដែរ" ។12

បងប្អូនប្រុសស្រីទាំងឡាយ សូមឱ្យយើងសួរខ្លួនឯងនូវសំណួរដែលបានចោទសួរឡើងទៅកាន់លោកវេជ្ជបណ្ឌិត ចាក ម៉ាក់ខូណេល និងបងប្អូនប្រុសស្រីរបស់គាត់នៅរៀងរាល់ពេលទទួលទានអាហារពេលល្ងាចថា : "តើនៅថ្ងៃនេះខ្ញុំបានធ្វើអ្វីខ្លះសំរាប់មនុស្សម្នាក់?" សូមពាក្យពេចន៍ស្រដៀងគ្នានេះនៅក្នុងទំនុកដំកើងចាក់ចូលទៅក្នុងដួងព្រលឹងរបស់យើង ហើយបានដក់ជាប់នៅក្នុងដួងចិត្តរបស់យើងជានិច្ច :

*តើនៅថ្ងៃនេះ ខ្ញុំបានធ្វើរឿងដ៏ល្អនៅក្នុងពិភពលោកនេះដែរឬទេ?*
*តើខ្ញុំបានជួយដល់នរណាម្នាក់ដែលត្រូវការជំនួយដែរឬទេ?*
*តើខ្ញុំបានលួងលោមអ្នកសោកសៅ ហើយបានធ្វើឱ្យនរណាម្នាក់មានអារម្មណ៍រីករាយដែរឬទេ?*
*បើមិនដូច្នោះ ខ្ញុំពិតជាបរាជ័យហើយ ។*
*តើនៅថ្ងៃនេះ ខ្ញុំបានមានឆន្ទៈ*
*ដើម្បីជួយសំរាលដល់បន្ទុករបស់នរណាម្នាក់ដែរឬទេ?*
*តើអ្នកឈឺ និងអ្នកមានទុក្ខព្រួយត្រូវបានជួយស្របតាមសេចក្ដីត្រូវការរបស់ពួកគេដែរឬទេ?*
*នៅពេលត្រូវការជំនួយរបស់ខ្ញុំ តើខ្ញុំបាននៅទីនោះដែរឬទេ?*13

ការបំរើនោះដែលយើងរាល់គ្នាត្រូវបានហៅ គឺជាការបំរើរបស់ព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទ ។

នៅពេលទ្រង់ដាក់បញ្ចូលយើងទៅក្នុងកិច្ចការរបស់ទ្រង់ នោះទ្រង់បានអញ្ជើញយើងឱ្យខិតចូលមកជិតទ្រង់ ។ ទ្រង់មានបន្ទូលមកកាន់អ្នករាល់គ្នា ហើយនឹងរូបខ្ញុំថា :

"អស់អ្នកដែលនឿយព្រួយ ហើយផ្ទុកធ្ងន់អើយ ចូរមកឯខ្ញុំ ខ្ញុំនឹងឱ្យអ្នករាល់គ្នាឈប់សំរាក ។

"ចូរទទួលនឹមខ្ញុំ ហើយរៀននឹងខ្ញុំចុះ ត្បិតខ្ញុំស្លូត ហើយមានចិត្តសុភាព នោះអ្នករាល់គ្នានឹងបានសេចក្ដីសំរាកដល់ព្រលឹង ។

"ពីព្រោះនឹមខ្ញុំងាយទេ ហើយបន្ទុកខ្ញុំក៏ស្រាល" ។14

បើយើងត្រងត្រាប់ស្ដាប់ដោយយកចិត្តទុកដាក់ នោះយើងនឹងឮសម្លេងពីទីឆ្ងាយនិយាយមកកាន់យើង ដូចដែលសម្លេងនេះទៅកាន់អ្នកដទៃផងដែរថា "ប្រពៃហើយ បាវល្អស្មោះត្រង់អើយ" ។15

ខ្ញុំសូមអធិស្ឋានថា ឱ្យយើងម្នាក់ៗអាចមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដើម្បីទទួលបានពរជ័យនេះពីព្រះអម្ចាស់ នៅក្នុងព្រះនាមរបស់ទ្រង់ ជាព្រះយេស៊ូវគ្រីស្ទ និងជាព្រះអង្គសង្គ្រោះរបស់យើង អាម៉ែន ។

កំណត់ចំណាំ

1. Jack McConnell "And What Did You Do for Someone Today?" *Newsweek* ថ្ងៃទី 18 ខែ មិថុនា ឆ្នាំ 2001 ទំព័រ 13 ។

1. Jack McConnell "And What Did You Do for Someone Today?" *Newsweek* ថ្ងៃទី 18 ខែ មិថុនា ឆ្នាំ 2001 ទំព័រ 13 ។

1. Jack McConnell "And What Did You Do for Someone Today?" *Newsweek* ថ្ងៃទី 18 ខែ មិថុនា ឆ្នាំ 2001 ទំព័រ 13 ។

1. Jack McConnell "And What Did You Do for Someone Today?" *Newsweek* ថ្ងៃទី 18 ខែ មិថុនា ឆ្នាំ 2001 ទំព័រ 13 ។

2. Jack McConnell "And What Did You Do for Someone Today?" ទំព័រ 13 ។

3. កាឡាទី 5:13 ។

4. ម៉ូសាយ 2:17 ។

5. លូកា 9:24 ។

6. David O. McKay នៅក្នុង Conference Report ខែ តុលា ឆ្នាំ 1963 ទំព័រ 8 ។

7. យេរេមា 8:22 ។

8. ម៉ូសាយ 18:8 ។

9. មិនស្គាល់ឈ្មោះ ដកស្រង់នៅក្នុង Richard L. Evans "The Quality of Kindness" *Improvement Era* ខែ មិថុនា ឆ្នាំ 1960 ទំព័រ 340 ។

10. សូមមើល Gerry Avant "Prophet's Birthday" *Church News* ថ្ងៃទី 23 ខែ សីហា ឆ្នាំ 2008 ទំព័រ 4 ។

11. Richard L. Evans "Living into Loneliness" *Improvement Era* ខែ កក្កដា ឆ្នាំ 1948 ទំព័រ 445 ។

12. ម៉ាថាយ 25:34--40 ។

13. "Have I Done Any Good?" *Hymns* ទំព័រ 223 ។

14. ម៉ាថាយ 11:28--30 ។

15. ម៉ាថាយ 25:21 ។